**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អភិបូជាសំណាក់ធម៌បូជាចារ្យតូមិនាគភ្នំពេញ**
**ភ្នំពេញថ្មី ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០**

# តើព្រះយេស៊ូទន្ទឹងរង់ចាំអ្វីពីខ្ញុំ?

**អត្ថបទទី១៖ យេរេមី ១៨,១៨-២០**

ពុំដែលមាននរណាប្រព្រឹត្តអំពើអាក្រក់ តបនឹងអំពើល្អទេ។ យរ ១៨,២០ក

**ដំណឹងល្អ៖ ម៉ាថាយ ២០,១៧-២៨**

បើមានអ្នកណាម្នាក់ចង់ធ្វើមេគេក្នុងចំណោមអ្នករាល់គ្នា អ្នកនោះត្រូវធ្វើជាខ្ញុំបម្រើរបស់អ្នករាល់គ្នាសិន។ មថ ២០,២៧

បងប្អូនជាទីស្រឡាញ់!

អត្ថបទដែលយើងបានស្តាប់ថ្ងៃនេះ ណែនាំឲ្យយើងនឹកឃើញជីវិតយើង ព្រះយេស៊ូដែលខិតខំនិយាយអំពីរឿងសំខាន់របស់ព្រះអង្គ ជិតត្រូវគេចាប់ គេវៃ គេសម្លាប់ និងមានព្រះជន្មរស់ឡើងវិញ។ ប៉ុន្តែ ម្តាយរបស់លោកយ៉ាកុបនិងលោកយ៉ូហានចេះតែគិតធ្វើដូចម្តេចដើម្បីឲ្យកូនគាត់មានកន្លែងល្អនៅខាងស្តាំខាងឆ្វេងព្រះយេស៊ូ មិនបានចូលនៅក្នុងរឿងដ៏សំខាន់ដែលព្រះយេស៊ូកំពុងនិយាយ។ ជីវិតរបស់យើង ជាបូជាចារ្យជួនកាលដូចគ្នាដែរយើងខិតខំរៀបចំអប់រំ ខិតខំរៀបចំសកម្មភាព ខិតខំណែនាំ ប៉ុន្តែបងប្អូនទទួលអ្វីដែលយើងកំពុងរៀបចំ គេមានគំនិតផ្សេងនៅឆ្ងាយពីអ្វីដែលយើងបានយកចិត្តទុកដាក់។ ម្នាក់ៗយើងមានបញ្ហាផ្ទាល់ខ្លួន ជួនកាលយើងឈឺចិត្តដែរយើងខិតខំរៀបចំនេះរៀបចំនោះចុងក្រោយគ្មានអ្នកចាប់អារម្មណ៍។ ព្រះយេស៊ូប្រហែលមានគម្រោងការពិសេសសម្រាប់ជីវិតរបស់យើងផ្ទាល់ ព្រះបន្ទូលប្លែកដែលព្រះយេស៊ូមានតាមរយៈព្រះសហគមន៍ និងតាមរយៈបងប្អូន ប្រហែលយើងគិតអ្វីផ្សេងដែលឆ្ងាយពីអ្វីដែលព្រះយេស៊ូរង់ចាំពីយើង។

រដូវ៤០ថ្ងៃ ជាពេលវេលាមួយដើម្បីឲ្យយើងទាំងអស់ជាបូជាចារ្យ ជាគ្រីស្តបរិស័ទ ឲ្យយើងកែប្រែចិត្តគំនិតថែមទៀត ខិតខំចូលជ្រៅនៅក្នុងព្រះបន្ទូលដែលព្រះយេស៊ូមានសម្រាប់យើងផ្ទាល់។ យើងយកចិត្តទុកដាក់នឹងព្រះបន្ទូលនេះ កុំឲ្យអារម្មណ៍យើងទៅដល់តែបញ្ហាផ្ទាល់ខ្លួន ប៉ុន្តែឲ្យយើងមើលឃើញអ្វីដែលព្រះយេស៊ូទន្ទឹងរង់ចាំពីយើង។ ដោយដឹងថាអ្វីដែលព្រះយេស៊ូទន្ទឹងរង់ចាំពីយើង ជួនកាលយើងត្រូវការឆ្លងកាត់ទុក្ខលំបាកដូចព្រះយេស៊ូផ្ទាល់ ប៉ុន្តែណែនាំឲ្យយើងរកឃើញជីវិតដ៏បរិបូណ៌។ ដូចព្រះយេស៊ូមានព្រះបន្ទូល នៅពេលគេធ្វើបាបព្រះអង្គបីថ្ងៃក្រោយមកព្រះអង្គមានព្រះជន្មរស់ឡើងវិញ។ ពីរថ្ងៃកន្លងមកដែលយើងបានជួបជុំគ្នា សម្រាប់យើងជា

បូជាចារ្យយើងបានចូលនៅក្នុងតួនាទីដែលយើងទទួល តាមមណ្ឌលសកម្មភាពនីមួយៗយើងទទួលតួនាទីទាំងបីដែលលោកអភិបាលទទួល។

**ទីមួយ** ណែនាំឲ្យប្រជារាស្ត្ររបស់ព្រះអង្គទៅជាប្រជារាស្ត្រដ៏វិសុទ្ធ អប់រំគេឲ្យស្គាល់ជំនឿ ឲ្យស្គាល់ប្រពៃណី ឲ្យស្គាល់ជីវិតនៃព្រះសហគមន៍

**ទីពីរ** ថែរក្សាធម៌មេត្តាករុណារបស់ព្រះអង្គ ដើម្បីណែនាំឲ្យមនុស្សទាំងអស់អាចស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គយ៉ាងពិតប្រាកដ

**ទីបី** ផ្នែកគ្រប់គ្រង យើងត្រូវការគ្រប់គ្រងព្រះសហគមន៍យើង គ្រប់គ្រងហិរញ្ញវត្ថុដែលយើងទទួល និងគ្រប់គ្រងបងប្អូនដែលយើងទទួល។

ជីវិតរបស់យើង ជាជីវិតពិសេសដែរយើងទទួលតួនាទីផ្សេងៗគ្នាតែនៅក្នុងគោលដៅតែមួយ គឺណែនាំឲ្យបងប្អូនដែលយើងទទួលអាចស្គាល់ជីវិតដែលព្រះជាម្ចាស់ប្រទានឲ្យ ជាពិសេសព្រះយេស៊ូដែលសោយទិវង្គតនិងមានព្រះជន្មរស់ឡើងវិញ។ យើងអធិដ្ឋាន ដើម្បីឲ្យយើងជាលោកអភិបាល លោកបូជាចារ្យ យើងទទួលខុសត្រូវយ៉ាងខ្ពស់លើតួនាទីរបស់យើង ក្នុងការណែនាំបងប្អូនឲ្យទៅជាបងប្អូនដ៏វិសុទ្ធ ដើម្បីណែនាំឲ្យសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ទៅដល់គ្រប់ទីកន្លែង។ និងដើម្បីគ្រប់គ្រងអស់ពីសមត្ថភាពឲ្យគម្រោងការរបស់ព្រះជាម្ចាស់ ដែលណែនាំឲ្យមនុស្សយើងរកឃើញសេចក្តីសុខ អាចកើតឡើងនៅលើផែនដីនេះ។ ដូច្នេះ យើងចូលនៅក្នុងសុបិនរបស់សម្តេចប៉ាប ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាព្រះសហគមន៍ដែលណែនាំវត្តមានរបស់ព្រះជាម្ចាស់គ្រប់ពេលវេលា។ អាម៉ែន៕